ព្រះរាជាណាចក្រកម្ពុជា

ខេត្តស្វាយរៀង

ជាតិ សាសនា ព្រះមហាក្សត្រ

ស្រុកស្វាយជ្រំ

ឃុំពោធិ៍រាជ

ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

លេខៈ ០០៧ ស ជ ណ

## សេចក្តីជូនដំណឹង

## មេឃុំពោធិ៍រាជ

សូមគោរពជូនដំណឹង ដល់បងប្អូនប្រជាពលរដ្ឋរស់នៅក្នុងឃុំពោធិ៍រាជទាំងមូលអោយបានជ្រាបថា ដោយយោងទៅលើស្មារតី ដែលរៀបចំឡើងនៅសហគមន៍ ភូមិព្រៃខ្លាស្តីពីការទប់ស្កាត់ ប្រើប្រាស់គ្រឿងស្រវឹងចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០០៩ ដូចនេះក្នុងនាមខ្ញុំជាមេឃុំពោធិ៍រាជ សូមជូនដំណឹងដូចខាងក្រោមៈ

១-មិនអោយជនណាម្នាក់ ទទួលទានគ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងទីវត្តអារាមសាលារៀន មណ្ឌលសុខភាព ។

២- មិនអនុញ្ញាត្តិ អោយជនណាម្នាក់ លើកបា៉ន់ល្បួផ្សព្វផ្សាយពាណិជ្ជកម្មលក់គ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងឃុំចម្ងាយពីវត្ត ឬ សាលារៀន ៣០០ ម៉ែត្រ ។

៣- ហាមលក់គ្រឿងស្រវឹងគ្រប់ប្រភេទ អោយក្មេងក្រោមអាយុ ១៦ ឆ្នាំ។

៤- ហាមអ្នកផឹកគ្រឿងស្រវឹងនៅក្នុងឃុំ កុំអោយហួសពេលវេលា កំណត់ ម៉ោង១០ យប់។

៥- ហាមអ្នកផឹកគ្រឿងស្រវឹងទាំងឡាយនៅក្នុងឃុំ អោយចេះគោរពច្បាប់ចរាចរណ៍ផ្លូវគោក ម្យ៉ាងទៀតដោយយល់ឃើញថា កុមារក្រោមអាយុ ១៨ ឆ្នាំ ជាទំពាំងស្នងឬស្សីរបស់ប្រទេសជាតិយើង ។

សូមកុំបង្ខំកុមារក្រោមអាយុ ១៦ ឆ្នាំ អោយទៅទិញស្រា ឬ ហូបគ្រឿងស្រវឹងឡើយ ។ និង អ្នកលក់ស្រា គួរកុំលក់ស្រាអោយអ្នកទិញណាដែលមានអាយុក្រោម ១៦ ឆ្នាំ ។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមអស់លោកស្រី និងប្រជាពលរដ្ឋទូរទាំងឃុំជ្រាប ជាពត៏មាន

មេឃុំពោធិ៍រាជ

ញ៉ឹក យុន